**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**
លេខសំណុំរឿងព្រហ្មទណ្ឌៈ ១១៤២
ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១
សំណុំរឿងជំនុំជម្រះលេខៈ ៦១៧
ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២
សាលក្រមលេខៈ **៦៧ (ឈ)/ ៧១២**
ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបើកសវនាការជាអសាធារណៈ នៅសាលាដំបូងខេត្តសៀមរាប សាលសវនាការក១ កាលបរិច្ឆេទបើកសវនាការ ថ្ងៃពុធ ២រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែតុលា ឆ្នាំ២០២២ វេលាព្រឹក។

កាលបរិច្ឆេទប្រកាសសាលក្រម ថ្ងៃពុធ ៩រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ វេលាព្រឹក។

### ក្រុមប្រឹក្សាជំនុំជម្រះ

| | | |
|---|---|---|
| លោក | [redacted] | ប្រធានក្រុមប្រឹក្សា |
| លោកស្រី | | ចៅក្រមប្រឹក្សា |
| លោក | | ចៅក្រមប្រឹក្សា |

### តំណាងអយ្យការ

| | | |
|---|---|---|
| លោកស្រី | [redacted] | ព្រះរាជអាជ្ញារង |

### ក្រឡាបញ្ជីសវនាការ

| | | |
|---|---|---|
| លោកស្រី | [redacted] | ក្រឡាបញ្ជី |

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ ១១៤២ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២១ និងសំណុំរឿងជំនុំជម្រះលេខ ៦១៧ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ ដែលមានជនជាប់ចោទៈ

-ឈ្មោះ [redacted] ជាន ហៅ ថ្លើម ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតនៅ[redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅផ្ទះ[redacted] ខេត្តសៀមរាប ឪពុកឈ្មោះ ធួក ម្តាយឈ្មោះ [redacted] សំបុទ នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី០៦ ។ (គេចខ្លួន)

ត្រូវបានជាប់ចោទពីបទ ៖ **រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅចំណុចដីឡូតិ៍ភូមិចំបក់ហែ ឃុំពួក ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

-លោក [redacted] ជាមេធាវីការពារសិទ្ធឲ្យជនជាប់ចោទឈ្មោះ[redacted] ជាន។

## ភាគីដើមបណ្តឹងរដ្ឋប្បវេណី

- ឈ្មោះ [redacted]រិន ភេទស្រី អាយុ៤៧ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិចំបក់ហែ ឃុំពួក ស្រុកពួក ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិចំបក់ហែ ឃុំពួក ស្រុកពួក ខេត្តសៀមរាប។

- ជនរងគ្រោះឈ្មោះ [redacted] ធាន ភេទស្រី កើតថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិចំបក់ហែ ឃុំពួក ស្រុកពួក ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិចំបក់ហែ ឃុំពួក ស្រុកពួក ខេត្តសៀមរាប។

- លោកស្រី [redacted] ជាមេធាវីការពារសិទ្ធឲ្យជនរងគ្រោះឈ្មោះ [redacted] ធាន។

- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤៥៩ អយក/២២ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប។

- បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣១៩៣ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប។

- បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ ៦៣២ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តសៀមរាប។

## អង្គហេតុកើតមានឡើងដូចតទៅ:

កាលថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ២៣ និង ៣០ នាទី នៅចំណុចដីឡូតិ៍ស្ថិតនៅភូមិចំបក់ហែ ឃុំពួក ស្រុកពួក ខេត្តសៀមរាប មានករណីរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] ជាន ហៅ ថ្លើម ភេទប្រុស អាយុ២៣ឆ្នាំ។ នៅពេលកំពុងធ្វើសកម្មភាពរួមភេទជាមួយជនរងគ្រោះឈ្មោះ [redacted] ធាន ស្រាប់តែម្តាយរបស់ជនរងគ្រោះមកទាន់ ហើយជនសង្ស័យឈ្មោះ [redacted] ជាន បានគេចខ្លួនបាត់។ ជាក់ស្តែងតាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ធាន បានឆ្លើយថាកន្លងមកខ្លួនធ្លាប់បានរួមភេទជាមួយជនសង្ស័យឈ្មោះ [redacted] ជាន បានម្តង គឺនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ១១យប់ នៅចំណុចដីឡូតិ៍ខាងជើងផ្ទះរបស់ជនរងគ្រោះ។ តាមការពិនិត្យមើលសំបុត្រកំណើតរបស់ជនរងគ្រោះឈ្មោះ [redacted] ធាន បានកើតនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ ដែលគិតមកដល់ថ្ងៃកើតហេតុមានអាយុ១៣ឆ្នាំ។ ក្រោយមកម្តាយរបស់ជនរងគ្រោះក៏បានដាក់ពាក្យបណ្តឹងមកកាន់អធិការដ្ឋាននគរបាលស្រុកពួក ហើយសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងខេត្តសៀមរាប ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

## សិទ្ធិនិយាយស្តីរបស់ភាគី បន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល

- លោកស្រី [redacted] ជាមេធាវីការពារសិទ្ធឲ្យជនរងគ្រោះឈ្មោះ [redacted] ធាន បានធ្វើសេចក្តីសន្និដ្ឋានការពារថា ៖ ក្រោយពីពិនិត្យទៅលើសំណុំឯកសារ និងការដេញដោលតាមចម្លើយរបស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ឃើញថាពិតជាមានសកម្មភាពរួមភេទជាមួយអនីតិជនពិតប្រាកដមែន។ ផ្អែកតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន ការរួមភេទដែលធ្វើឡើងដោយអនីតិជនអាយុក្រោម១៥ឆ្នាំ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ ដូច្នេះហើយស្នើសុំដល់អង្គជំនុំជម្រះមេត្តាសម្រេចតាមបញ្ញត្តិច្បាប់ និងសងសំណងទៅតាមការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី។

- តំណាងអយ្យការបានសន្និដ្ឋានប្តឹងសុំ ៖ ឆ្លងតាមកិច្ចពិភាក្សាដេញដោលរួចមកឃើញថាជនជាប់ចោទពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតប្រាកដមែន។ តាងនាមតំណាងអយ្យការ ស្នើសុំរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ៤៥៩ អយគ/២២ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប និងប្តឹងសុំឲ្យចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

- លោក [redacted] ជាមេធាវីការពារសិទ្ធឲ្យជនជាប់ចោទឈ្មោះ [redacted] **ជាន** បានធ្វើសេចក្តីសន្និដ្ឋានការពារថា ៖ ផ្អែកទៅតាមការសួរដេញដោល និងតាមចម្លើយរបស់ជនរងគ្រោះគ្រប់ដំណាក់កាល ឃើញថាជនរងគ្រោះពិតជាបានស្រឡាញ់គ្នាពិតប្រាកដ និងបានព្រមព្រៀងគ្នាក្នុងការរួមភេទ និងផ្អែកតាមការធ្វើកោសលវិច្ឆ័យក៏មិនឃើញមានការដាច់រលាត់នោះដែល។ ដូច្នេះស្នើសុំឲ្យតុលាការធ្វើការបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំបាទផង។

**<u>ផ្អែកតាមកិច្ចពិភាក្សាដេញដោល</u>**

- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រិន
- ក្រោយពីបានស្តាប់ចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ធាន
- ក្រោយពីបានពិនិត្យភស្តុតាងជាឯកសារដែលបានកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធឲ្យជនរងគ្រោះ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធឲ្យជនជាប់ចោទ
- ក្រោយពីបានពិនិត្យ ពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់

**<u>សំអាងហេតុ</u>**

- តាមរយៈដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣១៩៣ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ដែលបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ជាន ទៅជំនុំជម្រះពីបទៈ **រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅចំណុចដីឡូតិ៍ ភូមិចំបក់ហែ ឃុំពួក ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

- នាពេលសវនាការដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រិន បានឆ្លើយបំភ្លឺថា៖ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោងប្រហែល១១យប់ ខ្លួនបានលឺសម្លេងកូនស្រីរបស់ខ្លួនឈ្មោះ [redacted] ធាន អាយុ១៣ឆ្នាំ បាននិយាយទូរស័ព្ទ។ ពេលនិយាយទូរស័ព្ទរួច កូនខ្លួនបានដើរចេញពីផ្ទះ ហើយខ្លួនមានការសង្ស័យក៏បាននាំកូនស្រីម្នាក់ទៀតឈ្មោះ ជា ដើរកាន់ភ្លើងកែវឈ្មួលដល់ចំណុចដីឡូតិ៍ខាងជើងផ្ទះ ស្រាប់តែឃើញមានម៉ូតូក្មេងប្រុសជិះម្នាក់ឯងចេញទៅបាត់ ហើយបានឃើញកូនស្រីរបស់ខ្លួនឈ្មោ [redacted] ធាន បានដើរចេញមក។ បន្ទាប់មកខ្លួននាំកូនស្រីឈ្មោះ [redacted] ធាន ទៅផ្ទះ និងសួរនាំរឿងហេតុទើបកូនស្រីខ្លួនឈ្មោះ [redacted] ធាន បានប្រាប់ថារូបនាងមានទំនាក់ទំនងស្នេហាជាមួយប្រុសឈ្មោះ [redacted] ជាន ហៅ ថ្លើម (ជាអ្នកភូមិតាទុក ឃុំពួក ស្រុកពួក ខេត្តសៀមរាប)។ ពួកគេបានស្គាល់គ្នាតាមរយៈទូរស័ព្ទ និងបណ្តាញសង្គមហ្វេសប៊ុក និងបានណាត់ជួបគ្នាបានចំនួន០៤លើក។ កូនស្រីខ្លួនបន្ថែមថា នៅពេលណាត់ជួបគ្នាម្តងៗគឺឈ្មោះ [redacted] ជាន បានធ្វើសកម្មភាពអោបថើប ស្ទាប



Scanned with CamScanner

អង្អែលលេងសុដន់ និងលេងប្រដាប់ភេទរបស់នាង និងធ្លាប់រួមភេទជាមួយនាងបានម្តង ក្រោយមក ពុំបានរួមភេទទៀតទេ ដោយសារខ្លាចគេតាមទាន់ រហូតដល់ថ្ងៃកើតហេតុ គឺខ្លួនបានមកទាន់ទើបឈ្មោះ [redacted] ជាន ឡើងជិះម៉ូតូគេចទៅបាត់។ ខ្លួនស្នើសុំឲ្យភាគីជនល្មើសចូលមកដោះស្រាយ និងទទួលខុសត្រូវចំពោះកូនស្រីរបស់ខ្លួន ព្រមទាំងទាមទារសំណងជម្ងឺចិត្តចំនួន ៥,០០០$ (ប្រាំពាន់) ដុល្លារអាមេរិក។

- នាពេលសវនាការជនរងគ្រោះឈ្មោះ [redacted] ធាន បានឆ្លើយបំភ្លឺថា៖ នៅអំឡុងខែកញ្ញា ឆ្នាំ២០២១ ខ្លួនបានស្គាល់ឈ្មោះ [redacted] ជាន ហៅ ថ្លើម តាមរយៈទូរស័ព្ទ និងតាមបណ្តាញសង្គមហ្វេសប៊ុក (ហ្វេសប៊ុកខ្លួនឈ្មោះ អូនតឿស្រុកពួក ចំណែកហ្វេសប៊ុករបស់ឈ្មោះ [redacted] ជាន គឺដាក់ឈ្មោះ [redacted] Na តាំងរូបរបស់គេផ្ទាល់)។ បន្ទាប់ពីខ្លួនស្គាល់ឈ្មោះ [redacted] ជាន ហៅ ថ្លើម តាមរយៈទូរស័ព្ទ និងបណ្តាញសង្គមហ្វេសប៊ុករួចហើយ ពួកខ្លួនក៏បានណាត់ជួបគ្នានៅចំណុចដីឡូតិ៍ខាងជើងផ្ទះរបស់ខ្លួន ដោយខ្លួនលួចលាក់មិនឲ្យអ្នកណាដឹង។ នៅពេលទៅដល់ឈ្មោះ [redacted] ជាន បានអោបថើបលេងសុដន់ខ្លួន ហើយស្រាតខោអាវរបស់គេ បន្ទាប់មកឈ្មោះ [redacted] ជាន បានយកប្រដាប់ភេទរបស់គេដាក់ចូលប្រដាប់ភេទរបស់ខ្លួន បានប្រហែលប្រាំនាទីក៏ឈប់ ហើយពួកខ្លួនក៏ស្លៀកខោវិញរៀងៗខ្លួន និងត្រឡប់ទៅផ្ទះវិញ។ លើកទី២ ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ៨យប់ ពួកខ្លួនបានណាត់ជួបនៅខាងក្រោយផ្ទះរបស់ខ្លួនហើយឈ្មោះ [redacted] ជាន បានអោប ថើប ស្ទាប់សុដន់របស់ខ្លួន ប៉ុន្តែពុំទាន់បានរួមភេទទេ ដោយសារខ្លាចគេមកទាន់។ លើកទី៣ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង ៩យប់ ណាត់ជួបនៅចំណុចដីឡូតិ៍ខាងជើងផ្ទះរបស់ខ្លួន ហើយឈ្មោះ [redacted] ជាន បានធ្វើដូចលើកមុន ដោយអោប ថើប ស្ទាបសុដន់របស់ខ្លួន ប៉ុន្តែពុំបានរួមភេទនោះទេ ដោយខ្លួនខ្លាចគេមកទាន់ និងលើកទី៤ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ ពួកយើងបានណាត់ជួបគ្នាទៀត ហើយពេលដែលឈ្មោះ [redacted] ជាន កំពុងតែអោប ថើប និងយកដៃលូកចូលប្រដាប់ភេទខ្លួន ស្រាប់តែបងស្រី និងម្តាយរបស់ខ្លួនមកទាន់ ហើយឈ្មោះ [redacted] ជាន បានឡើងជិះម៉ូតូគេចខ្លួនបាត់ទៅ។ បន្ទាប់មកខ្លួនបានយករឿងនេះទៅប្រាប់ម្តាយ ហើយម្តាយខ្លួនបានដាក់ពាក្យបណ្តឹងទៅលើឈ្មោះ [redacted] ជាន។ ខ្លួនសូមបញ្ជាក់ថា ខ្លួនបានព្រមព្រៀងរួមភេទជាមួយឈ្មោះ [redacted] ជាន ដោយពុំមានការបង្ខិតបង្ខំ ឬ ប្រើប្រាស់អំពើហិង្សាមកលើខ្លួននោះទេ។ ប៉ុន្តែឈ្មោះ [redacted] ជាន បានសន្យាជាមួយខ្លួនថា រូបគេស្រលាញ់ខ្លួន និងយកខ្លួនធ្វើជាប្រពន្ធ ប៉ុន្តែឈ្មោះ [redacted] ជាន ពុំបានធ្វើការដូចការសន្យា ដោយរូបគេមិនទទួលខុសត្រូវលើរូបខ្លួន។ បច្ចុប្បន្នឈ្មោះ [redacted] ជាន នៅតែមានទំនាក់ទំនងតាមទូរស័ព្ទ ហើយខ្លួនបានប្រាប់ទៅឈ្មោះ [redacted] ជាន ចូលមកដោះស្រាយតែគាត់ពុំចូលមកទេ។ ខ្លួនសូមសំណូមពរ សុំឲ្យតុលាការមេត្តាជួយរកយុត្តិធម៌ដល់រូបខ្លួន និងសុំឲ្យឈ្មោះ [redacted] ជាន ទទួលខុសត្រូវលើរូបខ្លួនផង។

- តាមរបាយការណ៍សំយោគលេខ ២៥៥ ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកពួក បានបញ្ជាក់ថា៖ នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ២៣ និង ៣០នាទី ចំណុចដីឡូតិ៍ភូមិចំបក់ហែ ឃុំពួក ស្រុកពួក ខេត្តសៀមរាប មានករណីរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ លើក្មេងស្រីរងគ្រោះឈ្មោះ [redacted] ធាន ភេទស្រី កើតថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ (១៣ឆ្នាំ) រៀនថ្នាក់ទី៤ ប្រព្រឹត្តដោយជនសង្ស័យឈ្មោះ [redacted] ជាន ហៅ ថ្លើម ភេទប្រុស អាយុ២២ ឆ្នាំ រស់នៅភូមិតាទុក ឃុំពួក ស្រុកពួក ខេត្តសៀមរាប មុខរបរ កសិករ បានធ្វើសកម្មភាពរួមភេទ,

Scanned with CamScanner

អោប , ថើប , ស្ទាបលេងសុដន់ និងលេងប្រដាប់ភេទក្មេងស្រីរងគ្រោះចំនួន ០៤ លើក ដោយមានទំនាក់ទំនងស្នេហា។

- ជនជាប់ចោទឈ្មោះ [redacted] ផាន បានអវត្តមានគ្រប់ដំណាក់កាលនៃនីតិវិធី ប៉ុន្តែផ្អែកតាមចម្លើយជនរងគ្រោះឈ្មោះ [redacted] ឆាន បានបញ្ជាក់ថា៖ ខ្លួន និងជនជាប់ចោទឈ្មោះ [redacted] ផាន បានស្រលាញ់ និងទាក់ទងគ្នាយូរមកហើយ រហូតឈានដល់ការរួមភេទជាមួយគ្នា ដោយគ្មានការបង្ខិតបង្ខំនោះ គឺជាការឯកភាពគ្នាតែប៉ុណ្ណោះ។

- តាមការពិនិត្យទៅលើភស្តុតាងជាសំបុត្របញ្ជាក់កំណើតរបស់ជនរងគ្រោះឈ្មោះ [redacted] ឆាន លេខៈ ១១៦ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១២ ឃើញថា ជនរងគ្រោះឈ្មោះ [redacted] ឆាន កើតនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ នេះបញ្ជាក់ឲ្យឃើញថា ជនរងគ្រោះឈ្មោះ [redacted] ឆាន ទើបតែមានអាយុ១៣ឆ្នាំ គិតមកដល់ត្រឹមថ្ងៃកើតហេតុ ។ យោងតាមមាត្រា២៣៩ កថាខណ្ឌទី៣ នៃក្រមព្រហ្មទណ្ឌ បានចែងថា នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ។ ដោយផ្អែកទៅតាមចម្លើយរបស់ជនរងគ្រោះ និងភស្តុតាងជាសំបុត្រកំណើតរបស់ជនរងគ្រោះ ឃើញថាការរួមភេទរវាងជនជាប់ចោទ និងជនរងគ្រោះជា **អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ** តាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

- កាលពីអំឡុងថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ថិតនៅចំណុចដីឡូតិ៍ ភូមិចំបក់ហែ ឃុំពួក ស្រុកពួក ខេត្តសៀមរាប ពិតជាមានអំពើ **រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ** បានកើតឡើង ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ផាន ប្រាកដមែន។

- សេចក្តីសន្និដ្ឋានរបស់លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនរងគ្រោះឈ្មោះ [redacted] ឆាន បានស្នើសុំ៖ ៖ **តុលាការនឹងពិនិត្យ ពិចារណា សម្រេចតាមច្បាប់។**

- តំណាងអយ្យការបានសន្និដ្ឋានប្តឹងសុំ៖ រក្សាបទចោទតាមដីកាសន្និដ្ឋានស្ថាពរលេខ ៤៥៩ អយក/២២ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប និងប្តឹងសុំឲ្យចៅក្រមជំនុំជម្រះសម្រេចតាមច្បាប់ ឃើញថាការប្តឹងសុំនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ តុលាការ និងពិនិត្យពិចារណាចំពោះការប្តឹងសុំនេះ។

- សេចក្តីសន្និដ្ឋានរបស់លោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ផាន ហៅ ថ្លើម បានស្នើសុំ៖ ៖ **តុលាការនឹងពិនិត្យ ពិចារណា សម្រេចតាមច្បាប់។**

- ពុំមានភស្តុតាងណាមួយបញ្ជាក់ថាឈ្មោះ [redacted] ផាន ហៅ ថ្លើម មានបញ្ហាខាងស្មារតីនោះឡើយ ជនជាប់ចោទពិតជាបានយល់ដឹងអំពីផលវិបាកដែលកើតឡើងពីអំពើប្រព្រឹត្តរបស់ខ្លួន។

- មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ផាន ហៅ ថ្លើម ពីបទ៖ **រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅចំណុចដីឡូតិ៍ ភូមិចំបក់ហែ ឃុំពួក ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

Scanned with CamScanner

- អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ជាន ហៅ ថ្លើម ធ្វើឲ្យប៉ះពាល់ដល់សុខភាព កិត្តិយស សេចក្តីថ្លៃថ្នូរ រូបរាងកាយ សុវត្ថិភាពរបស់បុគ្គលឯកជន សន្តិសុខសណ្តាប់ធ្នាប់សង្គម និងប៉ះពាល់ដល់ច្បាប់របស់រដ្ឋ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រិន បានប្តឹងទាមទារសំណងជម្ងឺចិត្តជាប្រាក់ចំនួន ៥,០០០$ (ប្រាំពាន់) ដុល្លាអាមេរិក ឃើញថាការប្តឹងសុំនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការពិនិត្យ និងពិចារណា តាមព្យសនកម្មជាក់ស្តែង។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

**១-ផ្តន្ទាទោស ៖**

ឈ្មោះ [redacted] ជាន ហៅ ថ្លើម ភេទប្រុស អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ន [redacted] ទី៩ ភូមិតាទុក ឃុំពួក ស្រុកពួក ខេត្តសៀមរាប ឪពុកឈ្មោះ ធួក ម្តាយឈ្មោះ [redacted] សំបុទ នៅលីវ កម្រិតវប្បធម៌ថ្នាក់ទី០៦ **ដាក់ពន្ធនាគារកំណត់រយៈពេល ០៥ (ប្រាំ) ឆ្នាំ។**

ពីបទ ៖ **រួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ** ប្រព្រឹត្តនៅចំណុចដីឡូតិ៍ ភូមិចំបក់ហែ ឃុំពួក ស្រុកពួក ខេត្តសៀមរាប កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

**២-** បង្គាប់ឲ្យឈ្មោះ [redacted] ជាន សងសំណងជម្ងឺចិត្តចំនួន **៤,០០០,០០០ (បួនលាន) រៀល** ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រិន បណ្តឹងទាមទារលើសពីនេះបដិសេធចោលតាមមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**៣-** សាលក្រមនេះជំនុំជម្រះជាអសាធារណៈ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី។

- ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|

ហត្ថលេខា និងត្រា: [redacted]

**បានឃើញ**

ថ្ងៃពុធ ៩រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

សៀមរាប, ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២

**ប្រធានក្រុមប្រឹក្សា**

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ៩រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

សៀមរាប, ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២

**ក្រឡាបញ្ជីសវនាការ**

[redacted]

Scanned with CamScanner